archive.today
webpage capture
Saved from https://www.thmeythmey.com/?page=detail&id=83591 search
5 Aug 2021 08:43:51 UTC
no other snapshots from this url
All snapshots from host www.thmeythmey.com
Webpage Screenshot
share download .zip report bug or abuse donate

ជាតិ

ក្រុមហ៊ុនមួយ មានគម្រោងវិនិយោគលើការកែច្នៃស្វាយនៅកម្ពុជា

05, Oct 2019 , 10:59 pm

រូបភាព

លោក វ៉ង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម ក្នុងជំនួបជាមួយ លោក Ung Kim នាយកគ្រប់គ្រងនៅក្រុមហ៊ុន Cam M J Agricultural Park Co., Ltd នៅថ្ងៃទី៨តុលា។ (រូបភាព៖ហ្វេសប៊ុកលោក វ៉ង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម)

ដោយៈ *ឌុច សុភាព៍*

ក្រុមហ៊ុន Cam M J Agricultural Park Co., Ltd មានបំណងវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម (កែច្នៃស្វាយ) នៅប្រទេសកម្ពុជានៅក្នុងពេលឆាប់ៗនេះ។ គម្រោងនេះ ត្រូវបានលើកឡើងនៅក្នុងជំនួបពិភាក្សារវាង លោក វ៉ង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម ជាមួយ លោក Ung Kim នាយកគ្រប់គ្រងទូទៅនៃក្រុមហ៊ុន Cam M J Agricultural Park Co., Ltd កាលពីថ្ងៃទី៨តុលានេះ។

ហ្វេសប៊ុករបស់លោក វ៉ង បានស្រង់សម្តីលោក Ung Kim មកចុះផ្សាយថា ក្រុមហ៊ុននេះបានទទួលតោលការណ៍វិនិយោគពីCDC នៅដើមឆ្នាំ២០១៩ ដើម្បីសង់ Cam M J Agricultural Park Special Economic Zone លើផ្ទៃដីជិត១០០ហិកតា ស្ថិតនៅភូមិតានៃ ឃុំពើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ តំបន់ឧស្សាហកម្ម ដែលត្រូវបំណាយថវិកាប្រមាណ ១៥០លានដុល្លារ មានរយៈពេល៥ ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៥នេះ នឹងត្រូវធ្វើជាកន្លែងតាំងពិព័រណ៍កសិផល,ការប្រមូលទិញ,ការកែច្នៃផ្លែឈើត្រូពិក បន្ថែម, ការធ្វើជំនួញកសិផលជាមួយដៃគូឈានមុខអន្តរជាតិ និងជាកន្លែងអនុវត្តបច្ចេកទេសកសិកម្ម, ទីតាំងប្រមូលផ្តុំក្រុមផលិតពូជ និងការកែច្នៃផ្លែឈើរឹងៗ។ នេះបើតាមលោក Ung Kim។

ឆ្លើយតបនឹងគម្រោងវិនិយោគនេះ លោករដ្ឋមន្ត្រីក្រសួងកសិកម្ម អះអាងថាក្រសួងនឹងផ្តល់កិច្ចសហការគ្រប់បែបយ៉ាង ទាំងឯកសារអច្ចាល ច្បាប់ និងបច្ចេកទេស ធ្វើយ៉ាងណាឲ្យគម្រោងសម្រេចទទួលបានជោគជ័យ ដើម្បីមួយចំណែកលើកកម្ពស់សមត្ថភាពផ្គត់ផ្គង់កសិផលកែច្នៃលើទីផ្សារក្នុង និងក្រៅប្រទេស ប្រកួតប្រជែង ជំរុញការប្រើប្រាស់ និងកាត់បន្ថយការនាំចេញវត្ថុតាមដើមស្វាយ។ ក្រៅពីផលិតផលស្វាយ លោករដ្ឋមន្ត្រី ក៏បានប្រាប់ឲ្យក្រុមហ៊ុន គិតគូរវិនិយោគលើផលិតផលឯទៀតផងដែរ ដូចជាផលិតផលឯឡូងមី ម្រេច ស្វាយចន្ទី និងត្រីទឹកសាប។

សូមចុចត្រង់នេះដើម្បីអានថ្មីៗជាភាសាអង់គ្លេស (Cambodianess.com)

Tag: វិនិយោគ ថ្លៃស្វាយ

© រក្សាសិទ្ធិដោយ thmeythmey.com

អត្ថបទពេញនិយម

សារព័ត៌មានថ្មីៗ ជាដៃគូ
បំផុតសម្រាប់សហគ្រាស
យុគសម័យទំនើបនេះ
1 ថ្ងៃ

Advertising with Ca
to Reach Your Targ
Customers
3 ថ្ងៃ

ជម្រើសឈ្នួតផ្ទុក បែបថ្មី
ជាជើនប្រសេទជាមួយស
ប្រកបដោយប្រសិទ្ធភាព
2 ថ្ងៃ

«ស្ងើយនេនភាព»មាននិ
ដូចម្តេច?
1 សប្តាហ៍

សម្តេច ហ៊ុន សែនៃ សា
អនុវិទ្យាល័យអាចបើកថ្
ខែកញ្ញា ឬតុលា
4 ថ្ងៃ

© All Rights Reserved & Copyrights by THMEYTHMEY 2021
Hosting By: Thmey Thmey